# វ៉ាក់សាំង COVID-19 មានសុវត្ថិភាព និងប្រសិទ្ធភាព

## វិទ្យាសាស្ត្របង្ហាញច្បាស់ថា វ៉ាក់សាំងមានអត្ថប្រយោជន៍លើសលុបហានិភ័យ



### តើនរណាខ្លះដែលអាចចាក់វ៉ាក់សាំងបាន?

ជនគ្រប់រូបអាយុ 12 ឆ្នាំ និងលើសនេះ មានលក្ខណៈសម្បត្តិទទួលវ៉ាក់សាំងជំងឺកូវីដ-19។ វ៉ាក់សាំងដែលមានទាំងអស់ ពុំគិតកម្រៃទេ។

### តើវ៉ាក់សាំង COVID-19 មានប្រសិទ្ធភាពដែរឬទេ?

ត្រូវហើយ! ទិន្នន័យបច្ចុប្បន្នបង្ហាញថា វ៉ាក់សាំង Pfizer, Moderna និង J&J មានប្រសិទ្ធភាពខ្ពស់នៅក្នុងការទប់ស្កាត់ការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ការសម្រាកមន្ទីរពេទ្យ និងការស្លាប់ដោយសារជំងឺ COVID-19។ ដើម្បីទទួលអត្ថប្រយោជន៍ពេញលេញពីវ៉ាក់សាំង ជាការសំខាន់ដែលត្រូវចាក់វ៉ាក់សាំង Pfizer ឬ Moderna ទាំងពីរដូស។ បុគ្គលដែលមានប្រព័ន្ធការពាររាងកាយទន់ខ្សោយកម្រិតមធ្យម ឬកម្រិតធ្ងន់ធ្ងរ គួរពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់ខ្លួនអំពីថាតើ ពួកគាត់ត្រូវការចាក់ដូសទីបីដែរឬទេ។ វ៉ាក់សាំង J&J ត្រូវចាក់តែមួយដូសប៉ុណ្ណោះ។

### តើខ្ញុំគួរតែចាក់វ៉ាក់សាំងទោះបីមានវីរុសប្រភេទថ្មី ដូចជា Delta?

ត្រូវហើយ! វ៉ាក់សាំង Pfizer, Moderna, និង J&J មានប្រសិទ្ធភាពក្នុងការប្រឆាំងនឹងវីរុសប្រភេទ Delta ដែលទប់ស្កាត់ការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ការសម្រាកមន្ទីរពេទ្យ និងការស្លាប់ដោយសារជំងឺ COVID-19។ ការចាក់វ៉ាក់សាំងក៏ទប់ស្កាត់ឱកាសនៃការកើតមានវីរុសបំប្លែងថ្មីបន្ថែមទៀតផងដែរ។

### តើវ៉ាក់សាំង COVID-19 មានប្រសិទ្ធភាពដែរឬទេ?

ត្រូវហើយ!
រដ្ឋបាលអាហារ និងឱសថ (FDA) បានផ្តល់ការអនុញ្ញាតពេញលេញក្នុងការប្រើប្រាស់វ៉ាក់សាំង Pfizer លើបុគ្គលដែលមានអាយុចាប់ពី 16 ឆ្នាំឡើងទៅ កាលពីខែសីហា ឆ្នាំ2021 កន្លងទៅនេះ។ វ៉ាក់សាំង Pfizer ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់លើយុវជនអាយុចាប់ពី 12 ដល់ 15 ឆ្នាំផងដែរ។ វ៉ាក់សាំង J&J and Moderna ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគ្រាមានអាសន្ន (EUA) ពី FDA សម្រាប់បុគ្គលដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។ ការអនុញ្ញាតទាំងនេះគឺជាលទ្ធផលនៃការសាកល្បងវេជ្ជសាស្ត្រទ្រង់ទ្រាយធំទៅលើអ្នកចូលរួមជាច្រើននាក់។

### តើវ៉ាក់សាំងត្រូវបានបង្កើតឡើងដោយឆាប់រហ័សបែបនេះបានយ៉ាងដូចម្តេច?

ទោះបីវីរុសដែលបង្កឱ្យមានជំងឺ COVID-19 (SARS-CoV-2) ទើបតែត្រូវបានរកឃើញនៅក្នុងខែធ្នូឆ្នាំ2019 ក៏ដោយ អ្នកវិទ្យាសាស្ត្រជុំវិញពិភពលោកបានធ្វើកិច្ចការលើវ៉ាក់សាំងសម្រាប់វីរុសដែលមានការពាក់ព័ន្ធជិតស្និទ្ធបំផុតចាប់តាំងពីឆ្នាំ2006។ សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារការបង្កើតវ៉ាក់សាំងវីរុសកូរ៉ូណា។

### តើវ៉ាក់សាំង COVID-19 អាចបង្កផលប៉ះពាល់អ្វីខ្លះ?

មនុស្សមួយចំនួនបានទទួលរងផលប៉ះពាល់ដូចជាការឈឺចាប់បណ្តោះអាសន្ន ឬហើមនៅត្រង់ដៃដែលពួកគាត់បានចាក់វ៉ាក់សាំង ក្តៅខ្លួន រងាញាក់ អស់កម្លាំង និង/ឬឈឺក្បាល។ ផលប៉ះពាល់ទាំងនេះគឺជាបញ្ហាធម្មតាសម្រាប់គ្រប់វ៉ាក់សាំងទាំងអស់ ហើយរំពឹងថានឹងកើតឡើងនៅពេលរាងកាយបង្កើតកោសិកាដើម្បីការពារប្រឆាំងនឹងជំងឺ COVID-19 ។

ផលប៉ះពាល់ធ្ងន់ធ្ងរបន្ទាប់ពីចាក់វ៉ាក់សាំងការពារជំងឺ COVID-19 កម្រនឹងកើតឡើងណាស់។

FDA បានកំណត់ថា អត្ថប្រយោជន៍នៃវ៉ាក់សាំងនេះនៅតែមានអត្ថប្រយោជន៍លើសលុបហានិភ័យជាងការមិនបានចាក់វ៉ាក់សាំង។ មជ្ឈមណ្ឌលគ្រប់គ្រង និងការពារជំងឺ (CDC), American Heart និងបណ្ឌិត្យសភា American Academy of Pediatrics also Association ណែនាំឱ្យអ្នកដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ត្រូវទៅចាក់វ៉ាក់សាំង។ សម្រាប់ព័ត៌មានបន្ថែម សូមមើលចំណុចដែលត្រូវដឹងអំពីវ៉ាក់សាំង COVID-19 (CDC)។

### អ្នកគួរស្វែងរកការព្យាបាលជាបន្ទាន់ប្រសិនបើអ្នកមានរោគសញ្ញាណាមួយបន្ទាប់ពីបានចាក់វ៉ាក់សាំងដូចមានរៀបរាប់ខាងក្រោម ៖

ប្រភេទកំណកឈាមដ៏កម្រ ប៉ុន្តែធ្ងន់ធ្ងរ ជំងឺស្ទះសរសៃឈាមក្នុងខួរក្បាលដែលមានរោគសញ្ញា Thrombocytopenia (TTS) បានកើតឡើងចំពោះបុគ្គលមួយចំនួនតូចដែលបានចាក់វ៉ាក់សាំង J&J។ ការកើនឡើងនូវហានិភ័យ TTS មិនត្រូវបានរកឃើញដោយសារការចាក់វ៉ាក់សាំង Pfizer ឬ Moderna ឡើយ។ រោគសញ្ញារួមមាន ដកដង្ហើមខ្លី ឈឺទ្រូង ហើមជើង ឈឺពោះមិនព្រមបាត់ ឈឺក្បាលធ្ងន់ធ្ងរ ឬព្រិលភ្នែក ស្នាមជាំ ឬស្នាមឈាមតូចៗនៅក្រោមស្បែកហួសពីកន្លែងចាក់ថ្នាំ។

ករណីដ៏កម្រនៃ Guillain-Barré Syndrome (GBS) ក៏បានកើតឡើងចំពោះមនុស្សមួយចំនួនតូចដែចាក់វ៉ាក់សាំង J&J។ GBS គឺជាជំងឺប្រព័ន្ធប្រសាទដ៏កម្រមួយដែលអាចបណ្តាលឱ្យសាច់ដុំខ្សោយ ឬក្នុងករណីធ្ងន់ធ្ងរបំផុត គឺបណ្តាលឱ្យខ្វិន។ រោគសញ្ញាជាធម្មតាចាប់ផ្តើមរយៈពេលពី 1 ទៅ 2 សប្តាហ៍បន្ទាប់ពីការចាក់វ៉ាក់សាំង ប៉ុន្តែក៏អាចលេចឡើងនៅពេលក្រោយមកទៀតដែរ។ រោគសញ្ញាអាចរួមមានការចុះខ្សោយ ឬអារម្មណ៍ស្ពឹក ជាពិសេសនៅត្រង់ជើង ឬដៃ ដែលអាចកាន់តែធ្ងន់ធ្ងរ និងរាលដាលដល់ផ្នែកផ្សេងទៀតនៃរាងកាយ។

ក្នុងចំណោមពលរដ្ឋចំនួនជាង 150 លាននាក់ដែលបានចាក់វ៉ាក់សាំងពេញលេញជាមួយនឹងវ៉ាក់សាំង mRNA (Pfizer ឬ Moderna) គិតត្រឹមចុងខែកក្កដានេះ CDC បានបញ្ជាក់អំពីករណី 700 ករណីនៃជំងឺ myocarditis (រលាកសាច់ដុំបេះដូង) និង pericarditis (រលាកថង់នៅជុំវិញបេះដូង) )។ ករណីទាំងនេះភាគច្រើនកើតលើបុរសវ័យជំទង់ និងយុវជនដែលមានអាយុចាប់ពី 16 ឆ្នាំឡើងទៅ ក្នុងរយៈពេលពីរបីថ្ងៃបន្ទាប់ពីបានចាក់វ៉ាក់សាំងលើកទី 2។ រោគសញ្ញារួមមាន ឈឺទ្រូង ដកដង្ហើមញាប់ ឬមានអារម្មណ៍ថា ចង្វាក់បេះដូងលោតញាប់ ឬបេះដូងដើរញាប់ មនុស្សភាគច្រើនដែលទទួលបានសេវាថែទាំត្រឹមត្រូវមានការឆ្លើយតបយ៉ាងល្អចំពោះការព្យាបាល និងការសម្រាក និងមានអារម្មណ៍ធូរស្រាលយ៉ាងឆាប់រហ័ស។

សម្រាប់ពបន្ថែមសូមមើល Myocarditis និង Pericarditis បន្ទាប់ពី mRNA COVID-19 ការចាក់ថ្នាំបង្ការ (CDC)។

# វ៉ាក់សាំង COVID-19 មានសុវត្ថិភាព និងប្រសិទ្ធភាព

## វិទ្យាសាស្ត្របង្ហាញច្បាស់ថា វ៉ាក់សាំងមានអត្ថប្រយោជន៍លើសលុបហានិភ័យ



## តើវ៉ាក់សាំង COVID-19 មានសុវត្ថិភាពសម្រាប់ស្ត្រីមានផ្ទៃពោះនិង/ឬស្ត្រីកំពុងបំបៅដោះកូនដែរឬទេ?

ពិតណាស់! វ៉ាក់សាំង COVID-19 អាចជួយការពារពីជំងឺធ្ងន់ធ្ងរចំពោះស្ត្រីមានផ្ទៃពោះ និង/ឬស្ត្រីកំពុងបំបៅដោះកូន ដែលព្យាយាមមានផ្ទៃពោះ ឬអាចមានផ្ទៃពោះនៅពេលក្រោយ។ ដោយសារការផ្លាស់ប្តូរសារពាង្គកាយពីការមានផ្ទៃពោះ ស្ត្រីមានផ្ទៃពោះ និងស្ត្រីទើបមានផ្ទៃពោះថ្មីៗ ងាយនឹងមានជំងឺធ្ងន់ធ្ងរដោយសារជំងឺCOVID-19បើធៀបនឹងស្ត្រីពុំមានផ្ទៃពោះ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលវ៉ាក់សាំង COVID-19 សម្រាប់ស្ត្រីមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន (CDC)។

## តើនរណាខ្លះដែលត្រូវការវ៉ាក់សាំង COVID-19 ដូសបន្ថែម?

CDC កំពុងផ្តល់អនុសាសន៍ថាតើ បុគ្គលដែលមានប្រព័ន្ធការពាររាយកាយទន់ខ្សោយកម្រិតមធ្យម ឬធ្ងន់ធ្ងរ ទទួលបានវ៉ាក់សាំង mRNA ដូសទី 3 បន្ថែម។ ចំណុចនេះរួមបញ្ចូលទាំងបុគ្គលដែល៖

- កំពុងទទួលការព្យាបាលជំងឺមហារីកសកម្មសម្រាប់ដំបៅ ឬជំងឺមហារីកឈាម
- បានទទួលការប្តូរសរីរាង្គ និងកំពុងប្រើថ្នាំដើម្បីបង្ក្រាបប្រព័ន្ធការពាររាងកាយ
- បានទទួលការប្តូរកោសិកាដើម (Stem Cell) ក្នុងរយៈពេល 2 ឆ្នាំចុងក្រោយ ឬកំពុងប្រើថ្នាំដើម្បីបង្ក្រាបប្រព័ន្ធការពាររាងកាយ
- មានប្រព័ន្ធការពាររាងកាយបឋមទន់ខ្សោយកម្រិតមធ្យម ឬធ្ងន់ធ្ងរ (ដូចជាជំងឺ DiGeorge syndrome, Wiskott-Aldrich syndrome)
- ជំងឺអេដស៍ធ្ងន់ធ្ងរ ឬមិនបានទទួលការព្យាបាល
- ការព្យាបាលសកម្មដោយប្រើថ្នាំ corticosteroids កម្រិតដូសខ្ពស់ ឬថ្នាំផ្សេងទៀតដែលអាចបង្ក្រាបប្រព័ន្ធការពាររាងកាយរបស់អ្នក

ពលរដ្ឋគួរពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ខ្លួនអំពីថាតើការទទួលដូសបន្ថែមមានភាពសមស្របចំពោះខ្លួនដែរឬទេ។ មានតែអ្នកដែលបានទទួលវ៉ាក់សាំង Pfizer ឬ Moderna ពីរដូសប៉ុណ្ណោះដែលមានសិទ្ធិទទួលដូសទីបីបាន។ បច្ចុប្បន្នដូសបន្ថែមមិនត្រូវបានអនុញ្ញាតសម្រាប់វ៉ាក់សាំង J & J ទេ។

## តើនរណាខ្លះដែលមានអាចចាក់វ៉ាក់សាំង COVID-19 នៃដូសជំរុញ?

យោងតាម CDC ក្រុមមនុស្សខាងក្រោមដែលបានទទួលវ៉ាក់សាំង Pfizer ពីរដូសក្នុងរយៈពេលយ៉ាងតិច 6 ខែមុន គួរតែ ទទួលបានការចាក់វ៉ាក់សាំងដូសជំរុញ៖

អ្នកដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ

- ពលរដ្ឋគ្រប់វ័យដែលរស់នៅក្នុងបណ្តូថែទាំរយៈពេលវែង
- បុគ្គលដែលមានអាយុពី 50 ដល់ 64 ឆ្នាំដែលមានស្ថានភាពសុខភាពមិនបង្ហាញច្បាស់

ក្រុមពលរដ្ឋផ្សេងទៀតដែលអាចចាក់វ៉ាក់សាំងដូសជំរុញដោយផ្អែកលើហានិភ័យ និងអត្ថប្រយោជន៍នីមួយៗមានដូចខាងក្រោម៖

- បុគ្គលដែលមានអាយុពីចាប់ពី 18 ដល់ 49 ឆ្នាំ ដែលមានស្ថានភាពសុខភាពមិនបង្ហាញច្បាស់
- បុគ្គលដែលមានអាយុពីចាប់ពី 18 ដល់ 64 ឆ្នាំ ដែលមានហានិភ័យខ្ពស់ពីជំងឺ COVID-19 ដោយសារទីកន្លែងដែលពួកគាត់រស់នៅឬ ធ្វើការ

សូមពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ អ្នកប្រសិនបើអ្នកមិនច្បាស់អំពីថាតើ អ្នកត្រូវការចាក់វ៉ាក់សាំងដូសជំរុញដែរឬទេ។ អ្នកមិនចាំបាច់ត្រូវមាន “សេចក្តីបញ្ជាក់អះអាង” ពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកឡើយ ប្រសិនបើអ្នកស្ថិតនៅក្នុងក្រុមណាមួយដូចមានរៀបរាប់ខាងលើ។

សម្រាប់បន្ថែមទៀតអំពីអ្នកដែលអាចទទួលបានដូសជំរុញ សូមមើលចំណុច តើនរណាខ្លះមានសិទ្ធិចាក់វ៉ាក់សាំង COVID-19? (CDC)

## តើអ្នកដែលបានចាក់វ៉ាក់សាំង Moderna ឬ J & J អាចទទួលបានវ៉ាក់សាំ COVID-19 ដូសជំរុញដែរឬទេ?

FDA មិនបានអនុញ្ញាតឱ្យមានការចាក់ដូសជំរុញចំពោះអ្នកដែលចាក់វ៉ាក់សាំង Moderna ឬ J & J ឡើយ ប៉ុន្តែនឹងពិនិត្យមើលទិន្នន័យក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។

## តើខ្ញុំអាចចាក់វ៉ាក់សាំង COVID-19 នៅកន្លែងណាខ្លះ?

មានកន្លែងជាច្រើនដែលអ្នកអាចចាក់វ៉ាក់សាំង COVID-19 ដោយឥតគិតថ្លៃ។ គ្មានគ្លីនិកវ៉ាក់សាំងសហគមន៍ខោនធី Alameda ណាមួយដែលតម្រូវឱ្យមានអត្តសញ្ញាណប័ណ្ណ ធានារ៉ាប់រង ឬការណាត់ជួបណាមួយឡើយ។

សម្រាប់បញ្ជីពេញលេញនៃទីតាំងចាក់វ៉ាក់សាំងដែលនៅជិតអ្នក សូមើល Alameda County Vaccine Availability ឬមើល https://linktr.ee/AlamedaCountyOHE ។

សម្រាប់ជំនួយក្នុងការណាត់ជួបចាក់វ៉ាក់សាំងដោយឥតគិតថ្លៃ សូមទាក់ទងទៅលេខ 510-208-4VAX (510-208-4829)។


**ALAMEDA COUNTY HEALTH CARE SERVICES AGENCY**
**PUBLIC HEALTH DEPARTMENT**

Colleen Chawla – Agency Director
Kimi Watkins-Tartt – Director
Nicholas Moss, MD – Health Officer

**Contact**

Public Health Department:
(510) 267-8000 Main Line

COVID-19 Information:
(510) 268-2101

www.acphd.org